សៀវភៅណែនាំអំពី

# អក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថល





សហការផលិតដោយ

Smart

មូលនិធិ ស.អ.
CBRD Fund

បោះពុម្ពលើកទី១

# បុព្វបទ

ប្រព័ន្ធអ៊ិនធឺណិតជាពិភពមួយដ៏ទូលំទូលាយ។ ចាប់ពីវិស័យអប់រំ ពាណិជ្ជកម្ម ទៅកាន់វិស័យកម្សាន្ត ប្រព័ន្ធអ៊ិនធឺណិតធ្វើឲ្យជីវិតរបស់យើងមានភាពសប្បាយរីករាយ និងងាយស្រួលជាងមុន។ ការភ្ជាប់ទៅនឹង ប្រព័ន្ធអ៊ិនធឺណិតគឺជាឱកាសទៅកាន់ក្តីសុបិន្ត សេចក្តីប្រាថ្នាចង់បាន និងគោលដៅ រួមជាមួយនឹងឱកាសជាច្រើនរាប់មិនអស់។

ប៉ុន្តែប្រព័ន្ធអ៊ិនធឺណិតក៏អាចនាំមកនូវភាពគ្រោះថ្នាក់ដែរ ប្រសិនបើអ្នកមិនបានយល់ដឹងពីរបៀបរក្សាសុវត្ថិភាព និងការពារខ្លួន។ លើសពីវីរុស មែលវែរ (malware) និងការបោកបញ្ឆោតនៅលើប្រព័ន្ធអ៊ិនធឺណិត ហានិភ័យដែលប្រព័ន្ធអ៊ិនធឺណិតអាចនាំមកជាមួយ មានរូបភាពលើសពីអ្វីដែលបានលើកឡើងខាងលើនេះទៀត។

នៅក្រុមហ៊ុន SmartAxiata យើងមានឆន្ទៈក្នុងការសម្រេចបេសកម្មរបស់យើងក្នុងការភ្ជាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូច្នេះអ្នកគ្រប់គ្នាមិនថា នៅក្នុងកាលៈទេសៈណា ឬកន្លែងណាពួកគាត់នឹងនៅតែមានការភ្ជាប់ទៅនឹងប្រព័ន្ធអ៊ិនធឺណិតសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ប៉ុន្តែយើងមានគោលបំណងក្នុងការរក្សាសុវត្ថិភាពនៅពេលដែលអ្នកទាំងអស់គ្នាប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតដូច្នេះហើយយើងបានបង្កើតកម្មវិធីមួយចំនួនដើម្បីរក្សាសុវត្ថិភាពជូនប្រជាជនកម្ពុជាលើប្រព័ន្ធអ៊ិនធឺណិត។ ចាប់តាំងពីឆ្នាំ ២០១៩ កម្មវិធីអក្ខរកម្មឌីជីថល និងសុវត្ថិភាពលើប្រព័ន្ធអ៊ិនធឺណិត ត្រូវបានបង្កើតឡើងដោយរួមសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុន Smart Axiata សម្រាប់អប់រំសិស្សានុសិស្ស កម្រិតវិទ្យាល័យអំពីឱកាស និងបញ្ហាប្រឈមដែលមាននៅលើប្រព័ន្ធអ៊ិនធឺណិត។ ភាពជោគជ័យរបស់កម្មវិធីនេះត្រូវបានបញ្ជាក់កាន់តែច្បាស់ នៅពេលដែលកម្មវិធីនេះបានទទួលនូវ Social Empowerment award ពី Asia Responsible Enterprise Award។

ក្រោយពីភាពជោគជ័យរបស់កម្មវិធីនេះយើងមានឆន្ទៈក្នុងការពង្រីកចំណេះដឹងទៅកាន់មនុស្សជាច្រើនដូច្នេះពួកគាត់ដែលបានទទួលចំណេះដឹងទាំងនេះនឹងបានទទួលផលប្រយោជន៍ពីប្រព័ន្ធអ៊ិនធឺណិតបានកាន់តែទូលំទូលាយព្រមទាំងមានសុវត្ថិភាពកាន់តែប្រសើរ ដូចនេះហើយទើបយើងបង្កើតជាសៀវភៅគោលការណ៍ណែនាំនេះឡើង។

សៀវភៅគោលការណ៍ណែនាំនេះ ត្រូវបានបែងចែកជាពីរផ្នែក។ ផ្នែកទី១ ជាការពណ៌នាពីសាច់រឿងរបស់ក្មេងស្រីម្នាក់ លើដំណើរការនៃការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតរបស់នាង ហើយផ្នែកទី២ នៃសៀវភៅនេះរួមមានមាតិកាអប់រំ និងធនធានបន្ថែមផ្សេងៗអំពីឧបករណ៍ដែលមានប្រយោជន៍លើប្រព័ន្ធអ៊ិនធឺណិតសម្រាប់អ្នកអាន។ បន្ទាប់ទៀត អ្នកនឹងឃើញពីគន្លឹះសំខាន់ៗលើផ្នែកអក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវ ដែលរួមមានបញ្ចូលពីការរក្សាលេខសម្ងាត់ដើម្បីរក្សាទិន្នន័យផ្ទាល់ខ្លួន ស្របពេលដែលពួកគេប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ជាមួយនឹងការពន្យល់តាមរយៈរូបភាពដែលមានលក្ខណៈទាក់ទាញ ដែលបង្ហាញពីបទពិសោធន៍ជាក់ស្តែងដែលប្រជាជនកម្ពុជាប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត និងឧបករណ៍ឌីជីថលជាច្រើនផ្សេងទៀត។

ក្រុមការងាររបស់យើងសូមថ្លែងអំណរគុណដល់ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា រួមទាំងការគាំទ្រពីអ្នកផលិត និងអ្នកបង្កើតមាតិកា ដែលបានចូលរួមយ៉ាងសកម្ម និងធ្វើឱ្យកម្មវិធី និងសៀវភៅមួយនេះអាចចេញជារូបរាង និងផ្លែផ្កាបែបនេះ។

ក្រុមហ៊ុន Smart Axiata នឹងបន្តក្នុងការរក្សាឆន្ទៈដើម្បីចូលរួមចំណែកគាំទ្រដល់អក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវ ដូច្នេះទើបប្រជាជនកម្ពុជា អាចប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ប្រកបដោយសុវត្ថិភាព និងភាពរីកចំរើនទៅមុខ។

ក្រុមហ៊ុន Smart Axiata

រាជធានីភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ២០២២

## និពន្ធដោយ

ក្រុមហ៊ុន Smart Axiata, ប៉ែន ឧត្តម, អ៊ួងទី សាណា,
និង សៀង សុខចេង

**រូបភាពដោយ**

ប៉ែន ឧត្តម
Project lead | Comic development | Lead comic artist

អ៊ួងទី សាណា
Project lead | Comic development

ទូច សុនិច
Graphic designer

មាស វង្សលីណា
Comic colorist

ឆាង រតនៈ
Comic colorist

សៀង សុខចេង
Comic development

**មាតិកាណែនាំបន្ថែមអំពីអក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថល**
**ប្រកបដោយទំនួលខុសត្រូវដោយ**
ហម ឆលាង

# មាតិកា


កេសរ និងការប្រើប្រាស់ឧបករណ៍ឌីជីថលរបស់នាង 1-20

## មាតិកាណែនាំសម្រាប់ការប្រើប្រាស់ឧបករណ៍ឌីជីថល និងភាពជាពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវ

### ផ្នែកទី១: ភាពជាពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវ 22

1. របៀបបង្កើតពាក្យសម្ងាត់រឹងមាំ
2. ការស្វែងរកលើប្រព័ន្ធអ៊ីនធឺណិត
3. ការបោកប្រាស់លើប្រព័ន្ធអ៊ីនធឺណិត

### ផ្នែកទី២: ហ្គូហ្គល (Google) 28

1. ការបង្កើត Google Account
2. Google Drive
3. Google Docs
4. Google Slides
5. Google Sheets
6. Google Meet

### ផ្នែកទី៣: ជំហានសម្រាប់ការបង្កើត ទំព័រហ្វេសប៊ុក (Facebook Page) 36

### ផ្នែកទី៤: ការផលិតវីដេអូដោយប្រើប្រាស់ស្មាតហ្វូន (Smartphone) 38

1. Video Vox Pop
2. B-Roll Shooting
3. Video Shooting and Editing
4. Video Editing App Guidance

ឯកសារយោង និងធនធានផ្សេងៗ



វិទ្យាល័យបាត់ដំបង
៥:០៥ ល្ងាច
អេ! ដល់ម៉ោង ចេញហើយ!!
តោះៗ! ក្រែងទៅញ៉ាំអីហ្អី?
ទៅអត់?
អីមែន ភ្លេច! ទៅហើយៗ!
នៅទេ។ ផ្ញើមកៗ!
អឺ ចាំតិច!
ស៊ី! មានបានមើល វីដេអូនេះនៅ?
មើលម្នាក់នេះ POST ហ្អំ!
ឯង ទៅមុនហើយណា...
ទៅមែនទែនហើយ! ចាំមួយភ្លែត!!
អូខេ តោះៗ!!


សហការផលិតដោយ




សហការផលិតដោយ

មូលនិធិ ស.ឥ.
CBRD Fund






សហការផលិតដោយ
Smart
មូលនិធិ ស.អ.
CBRD Fund




សហការផលិតដោយ

មូលនិធិ ស.អ.
CBRD Fund




សហការផលិតដោយ

មូលនិធិ ស.ឥ.
CBRD Fund


បុងហ្វូរ!
ម-ម-មកទៀតហើយ!!
ហ៎ ហ៎ កំពុងធ្វើអីហ្នឹង?
ខ្ញុំចង់ចូលប្រកួតវីដេអូស្នាត ដែលនិយាយពីបញ្ហាសហគមន៍ តែមិនដឹងចាប់ផ្ដើមពីណាទៅណាទេ...
មានប្រធានបទហើយត្រូវអត់ ចឹងសាកចាប់ផ្ដើមស្រាវជ្រាវទៅ!
ស្លាប់ហើយ! មើលហ្វេសប៊ុក ព័ត៌មាន
អត់គួរឱ្យទុកចិត្តបានទាំងអស់ទេ!
NEWS PANDA
2h
2K
657 COMMENTS 257 SHARES
អ៊ីចឹងទៅរកនៅណា?
សាកប្រើ Google វិញមើល?
Google
សិស្សស្រី វិទ្យាល័យ បោះបង់ការសិក្សា
NOT SECURED
https://jeknev
https://km.m.wikipedia.or
https://opendevelopmentcambodia
ទេទេ
គ្រាន់បើ
ល្អ
វិគីភីឌា
គេហទំព័រនេះយ៉ាងម៉េចដែរ?
គេហទំព័រល្អ គឺជាទំព័រដែលមានសុវត្ថិភាពហើយ
ឯកសារយោងត្រឹមត្រូវដែលអាចស្រាវជ្រាវបន្តបាន!

សហការផលិតដោយ




**គួរចងចាំ:**

សាច់រឿងមិនមែនតែងតែកើតឡើងតាមលំដាប់ដូច ក ខ គ ឃ ង នោះទេ។ យើងអាចប្រើគំនិតច្នៃប្រឌិត ដើម្បីចាប់ផ្ដើមសាច់រឿងរបស់យើង។




សហការផលិតដោយ




សហការផលិតដោយ

Smart

មូលនិធិ ស.ស. CBRD Fund


ដងស្ទឹងសង្កែ
តាមពិត គ្នាចង់ផុសសម្រាប់ខ្លួនឯង និងមិត្តភក្តិទេ
គ្នាមានរឿងចង់ឱ្យកេសរឯងជួយ...
ឯងអត់ចង់ឱ្យគេផ្សេងឃើញ និង ខមមិនត៍លើរូបឯងនោះទេ
សុខ ស្រី
2D · PUBLIC
មានអារម្មណ៍ថាស្អាតប្លែក Today :)
37 LIKES
បានអាវពីណាដែរ sis?
10h LIKE REPLY
តប · 5 តបវិញ
ស្អាតដូចដំឡូងមូលមែន?
10h LIKE REPLY
តប · 2 តបវិញ
ពេលណាស្គម?
ឥឡូវធាត់ម្ល៉េះ??
មូលដូចដំឡូង

សហការផលិតដោយ


ខមមិនត៍ឈ្លើយៗម្ល៉េះ!
មិនសមនិយាយអ៊ីចឹងសោះ!
ឱ្យតែគ្នាផូសត៍រូបអីតិចតួច តែងតែមានខមមិនត៍អ៊ីចឹងរហូត...
រស្មី បណ្តាញសង្គមដែលយើងប្រើប្រាស់រាល់ថ្ងៃនេះហ្នា
អ្នកខមមិនត៍ទាំងនោះអាច ប្រើពាក្យមិនល្អ នៅ
ពេលខមមិនត៍ ពេលខ្លះថែមទាំងមានការចែក
រំលែកព័ត៌មានដែលខុសពីការពិតទៀតផង។
ឯងកុំចេះតែជឿមនុស្សដែលមិនស្គាល់ឡើយ! គ្រួសារឯង មិត្តឯង ព្រមទាំងខ្ញុំ សុទ្ធតែស្រឡាញ់ឯង!
ហើយគ្មានអ្វីដែលត្រូវផ្លាស់ប្តូរនោះទេ! យើងមិនគួរខ្វាយខ្វល់ជាមួយមនុស្សដែលយើងមិនស្គាល់ឡើយ។

សហការផលិតដោយ






១ ក្នុងបណ្តាញសង្គម កុំទទួលមនុស្សអត់ស្គាល់ជា មិត្តភក្តិ!!

២ ប្តូរ Privacy (ជ្រើសរើសទស្សនិកជន) ពេលបង្ហោះរូប ឬសារ

PUBLIC មានន័យថា សាធារណៈ គឺអ្នកណាក៏មើលរូបយើងឃើញដែរ! តែយើងអាចដូរវាបាន!!










សហការផលិតដោយ
មូលនិធិ ស.ឥ.
CBRD Fund


កេសរត្រឡប់ទៅផ្ទះម៉ោង ៥ ល្ងាច
ហឹម បញ្ហាដែលស្មីប្រាប់មិញ អាចជាប្រធានបទល្អហ្អេ
ប៉ា ម៉ាក់កូនមកវិញហើយ!
កូនឯងទៅហៅបុរីមកតិចមើល!
ហៅរាប់សិបដងនៅតែមិនលឺ!
ឃើញតែចុចនោះចុច!
ចាស...
បុរី! ម៉ែហៅស៊ីថ្ងាយហើយយើង!
អ៊ំ...

សហការផលិតដោយ


អូនឯងជួយមើលការងារផ្ទះផង
បាទ..
ល្មមៗបានហើយទូរសព្ទហ្នឹង...
បុរី...មិញម៉ាក់ហៅកូនច្រើនដងហើយ ម៉េចក៏អត់ឆ្លើយ?
...
ម៉ាក់និយាយហ្នឹង មិនមែនតែរឿងការងារផ្ទះទេ។ ទូរសព្ទហ្នឹង រប៉ះពាល់ដល់រឿងរៀន រឿងគេង និងសុខភាពកូនទៀតផង។ នៅផ្ទះជាមួយគ្នាសោះ តែមិនដែលឃើញមុខគ្នា។
ម៉ាក់និយាយអត់ខុសទេ មានអត្ថបទខ្លះគេថា លេងអ៊ិនធឺណិតច្រើនលើសកម្រិតធ្វើឱ្យយើងពិបាកផ្ចង់អារម្មណ៍ទៀតផង!
អូ ចឹងមែនហ្អបង?

សហការផលិតដោយ




សហការផលិតដោយ

Smart

មូលនិធិ ស.អ.
CBRD Fund


5:45 ព្រឹក
រៀបចំប្លង់
7:30 ព្រឹក
ចាប់ផ្ដើមថត
9:30 ព្រឹក
ដឹកនាំសម្ដែង
12:00 ថ្ងៃត្រង់
បាយថ្ងៃក្រោយថត
3 ថ្ងៃក្រោយមក...
វីដេអូប៉ុណ្ណឹង ពេញចិត្តនៅ?
ចាស!
យេ៎!!! ហើយៗ!!!
ពេលឈ្នះ កុំភ្លេចសែនឱ្យខ្ញុំផង!
ហ្អាក...ធ្វើចប់ហើយ គេធ្វើតាមណាទៅ?
បង្កើតវីដេអូផ្ទាល់ និងចែករំលែកតាម YouTube Channel របស់កេសរផ្ទាល់ ហ្នឹងហើយ!!!

សហការផលិតដោយ

1 ដោនឡូតកម្មវិធី តាមរយៈ YOUTUBE

Google Play
App Store




2 ចុះឈ្មោះនៅលើគណនី GOOGLE ACCOUNT

kesorsok05@gmail.com

3 បង្កើតគណនី CHANNEL YOUTUBE

រូបភាព

ឈ្មោះ:

បង្កើត CHANNEL

4 ផុសត៍វីដេអូ (UPLOAD VIDEO)



3:40

ចំណងជើង:

ពិពណ៌នាពីវីដេអូ



**ផុសត៍បានសម្រេច!! • UPLOAD SUCCESSFUL!!**

## 3 ថ្ងៃក្រោយមក...

SMART AXIATA

លទ្ធផលប្រកួតវីដេអូ របស់ក្រុមហ៊ុន SMART TOP 10

#SMART #TOP10 #វីដេអូអប់រំដើម្បីសហគមន៍

SMART TOP TEN VIDEOS

1. សុខ កេសរ
2. ចន្ទ វិទូ
3. គិច រចនា
6. រិទ្ធិ រក្សា
7. នួន ក្ញ៉ា
8. ជា រ៉ាវីជ

អ្នកជាប់ចំណាត់ថ្នាក់ TOP 10 ត្រូវចូលរួម LIVE អត្ថាធិប្បាយតាមកម្មវិធី Google Meet។

សហការផលិតដោយ

មូលនិធិ ស.អ.
CBRD Fund


តោះយើង រៀបចំចូលទៅ ក្នុង Google Meet!
ដូចជាភ័យអរ ភ័យអរយ៉ាងម៉េចទេ!!
កូនចាប់ផ្ដើមហើយ ម៉ាក់ ប៉ា!
ផ្សាយផ្ទាល់ 00 : 01
LIVE
ជ្រាបសួរអ្នកទាំងអស់គ្នា! ខ្ញុំឈ្មោះ កេសរ ខ្ញុំមកពីខេត្តបាត់ដំបង ជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យ បាត់ដំបង ខ្ញុំពិតជាមានកិត្តិយសណាស់ដែលត្រូវបានជ្រើសរើស សម្រាប់វគ្គផ្ដាច់ព្រ័ត្រ សម្រាប់ការបង្កើតវីដេអូ SMART នេះ ហើយថ្ងៃនេះ ខ្ញុំនឹងលើកបង្ហាញពីប្រធានបទ "**អក្ខរកម្មឌីជីថល**"។ អ៊ិនធឺណិត គឺជាប្រភពព័ត៌មានដ៏ធំធេង។ វាក៏ជាបណ្ដាញថ្មីមួយដែលចាំបាច់ក្នុងការរស់នៅជំនាន់ថ្មីផងដែរ ដូច្នេះហើយ យើងគួររៀនពីការវាយតម្លៃ និងជ្រើសរើសព័ត៌មានដែលគួរឱ្យជឿទុកចិត្ត។

សហការផលិតដោយ


ខ្ញុំយកប្រធានបទនេះ ព្រោះខ្ញុំចង់និយាយអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃបច្ចេកវិទ្យាអ៊ិនធឺណិត។ វាជាបណ្ដាញធំទូលំទូលាយ និងផ្ដល់ធនធានជាច្រើនដល់យើង។
ប៉ុន្តែ វាក៏មានគុណវិបត្តិភ្ជាប់មកជាមួយដែរ ប្រសិនបើយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ។ ខ្ញុំស្គាល់មនុស្សមួយចំនួនដែលមានបទពិសោធន៍ជាមួយនឹងការគំរាមកំហែងតាមអ៊ិនធឺណិត និងការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតហួសកំណត់។
មនុស្សគ្រប់គ្នាអាចសិក្សាតាមអ៊ិនធឺណិត។ ប៉ុន្តែមិនមែនគ្រប់គ្នា សុទ្ធតែចេះប្រើប្រាស់ និងគ្រប់គ្រងវាបានល្អនោះទេ។ ប្រសិនបើយើងប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតបានត្រឹមត្រូវ វានឹងជួយដល់ការសិក្សា និងការងាររបស់យើងទូទៅដែរ។ ដូច្នេះវាចាំបាច់ណាស់ដែលយើងត្រូវពិនិត្យមើលការប្រើប្រាស់របស់ពួកយើងមិនឱ្យហួសកំណត់ ចេះរក្សាឯកជនភាពនៅលើប្រព័ន្ធអ៊ិនធឺណិត ដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួនផងដែរ។ ទាំងនេះជាអ្វីដែលអ្នកអាចចាប់ផ្ដើមធ្វើបាន ក្នុងនាមជាពលរដ្ឋឌីជីថលប្រកបដោយការទទួលខុសត្រូវ។
LIVE


សូមអរគុណយ៉ាងខ្លាំងចំពោះការចូលស្ដាប់សុន្ទរកថារបស់ខ្ញុំ!
មួយអាទិត្យក្រោយមក...
កេសរឯងនិយាយបានល្អណាស់!
អរគុណកេសរ ដែលបានចែករំលែកបញ្ហានេះដល់អ្នកដទៃ។
ឌីង!
កេសរ ឯងជាប់ការប្រកួតធ្វើវីដេអូរបស់ SMART ហើយ!!
ថាម៉េច!!?
ជយោ!! ឯងប៉ារប្រហិតថ្ងៃនេះ!
យេ៎!
យេ៎!

សហការផលិតដោយ


ប៉ាម៉ាក់
ខ្ញុំមកវិញហើយ!
មកដល់ល្មមបាយហ្មំង!
អបអរសាទរកូន!
ថ្ងៃនេះជប់លៀង កូនបានជាប់លេខ! ទោះមិនជាប់លេខ១ ក៏ដោយ ក៏កូនបានជួយអ្នកជុំវិញនិង
សហគមន៍យើងឱ្យយល់ដឹងពីប្រធានបទទាក់ទងនឹងផលប្រយោជន៍
និងបញ្ហាប្រឈមរបស់ប្រព័ន្ធអ៊ិនធឺណិតដែរ។
អរគុណប៉ា! កូនជាប់ក៏ដោយសារប៉ុរី និងមិត្តកូនផងដែរ!!
ហើយក៏អរគុណ បងជំនាងផ្ទះដែរ។
រ៉ាក់អឺ!! មានរបស់ឆីថ្មី! ម៉េចដែរ
មានផែនការអីទៀតអត់?
ចាំតែមើលទៅ!

សហការផលិតដោយ

# មាតិកាណែនាំសម្រាប់ការប្រើប្រាស់ ឧបករណ៍ឌីជីថល និងភាពជាពលរដ្ឋ ឌីជីថលប្រកបដោយទំនួលខុសត្រូវ

# ផ្នែកទី១

## ភាពជាពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវ

ដូចទៅនឹងពិភពខាងក្រៅនៃប្រព័ន្ធអ៊ិនធឺណិតដែរ គោលការណ៍នៃភាពជាពលរដ្ឋល្អប្រកបដោយទំនួលខុសត្រូវ ត្រូវបានយកមកអនុវត្តតាមនៅលើប្រព័ន្ធ អ៊ិនធឺណិតដើម្បីឱ្យអ្នកទាំងអស់គ្នាប្រើប្រាស់ និងប្រាស្រ័យទាក់ទងគ្នាប្រកបទៅដោយទំនួលខុសត្រូវ និងសុវត្ថិភាព ដូច្នេះនៅពេលដែលអ្នកចូលរួមជាផ្នែកនៃសហគមន៍អ្នកប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតតាមកម្មវិធីផ្សេងៗដូចជា Facebook, Instagram, Google, YouTube, TikTok, Online Game និងកម្មវិធីផ្សេងៗទៀត អ្នកគួរតែអនុវត្តទៅតាមគោលការណ៍ដែលបានកំណត់នៅក្នុងកម្មវិធីទាំងនោះ។ ខាងក្រោមនេះជាចំណេះដឹងខ្លះៗ ដែលពលរដ្ឋឌីជីថលប្រកបដោយទំនួលខុសត្រូវគួរយល់ដឹងនៅពេលប្រើអ៊ិនធឺណិត។

*សម្រាប់ដំបូន្មាន និងឧបករណ៍ផ្សេងៗដែលអ្នកគួរតែយល់ដឹងបន្ថែមពេលប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត សូមស្វែងយល់លម្អិតតាមរយៈសៀវភៅ “កម្មវិធីសិក្សាអំពីភាពជាពលរដ្ឋឌីជីថល” របស់ Google ផ្ទាល់តាមតំណភ្ជាប់ (Link) នៅទំព័រឯកសារយោង។

តើអាចមានជម្លោះកើតឡើងដោយសារទំនាក់ទំនងនៅក្នុងសហគមន៍អ៊ិនធឺណិតដែរទេ? ហើយបើមាន ត្រូវធ្វើយ៉ាងណា?

**ចម្លើយគឺ** អាចមានជម្លោះកើតឡើងដោយសារទំនាក់ទំនងនៅក្នុងសហគមន៍អ៊ិនធឺណិត ហើយបើមាន សូមអនុវត្តដូចខាងក្រោម៖

- កុំឆ្លើយតប
- កុំសងសឹក
- ប្រើឧបករណ៍ដើម្បីរាយការណ៍ (report) ពីវា
- រក្សាភស្តុតាង
- ស្វែងរកជំនួយ

## ពាក្យសម្ងាត់រឹងមាំ

### ហេតុអ្វីត្រូវបង្កើតពាក្យសម្ងាត់ដែលរឹងមាំ?

ពាក្យសម្ងាត់ដូចជាកូនសោសំខាន់សម្រាប់ចូលទៅក្នុងគណនីដែលអ្នកបានបង្កើត។ នៅលើប្រព័ន្ធអ៊ិនធឺណិត មានមនុស្សរាប់លានអ្នកដែលកំពុងប្រើប្រាស់វាជារៀងរាល់ថ្ងៃ ដែលក្នុងនោះក៏មានជនខិលខូចផងដែរ។ ការដែលមានពាក្យសម្ងាត់មួយរឹងមាំ វាជួយឱ្យអ្នកគេចផុតពីជនខិលខូចណាដែលមានគំនិតលួចចូលគណនី (Hacker) របស់អ្នកក្នុងបំណងអាក្រក់ណាមួយ។




## របៀបបង្កើតពាក្យសម្ងាត់ដែលរឹងមាំ តែងាយចាំ

**វិធីសាស្ត្រទី១ (កម្រិតមូលដ្ឋាន)៖**

- រកនឹកប្រយោគដែលកំប្លែង និងងាយស្រួល។ ចាំ ដូចជា ចំណងជើងបទចម្រៀង ក្រុមបាល់ទាត់ សៀវភៅ ភាពយន្ត។ល។
- ជ្រើសរើសតួអក្សរដំបូងចេញពីពាក្យនីមួយៗនៅក្នុងប្រយោគ។
- ប្តូរតួអក្សរមួយចំនួនទៅជានិមិត្តសញ្ញា។
- កំណត់តួអក្សរមួយចំនួនឱ្យទៅជាតួអក្សរធំ និងមួយចំនួនជាតួអក្សរតូច។

**ឧទាហរណ៍**

ប្រយោគ: My cousin Laura has two dogs and one cat.

ពាក្យសម្ងាត់: McLh2D &1c

**វិធីសាស្ត្រទី២ (កម្រិតខ្ពស់)៖**

- រកនឹកពាក្យសម្ងាត់មេរឹងមាំដែលផ្អែកលើប្រយោគ។
- កែសម្រួលវាសម្រាប់គេហទំព័រ ឬកម្មវិធីទាំងឡាយដែលអ្នកប្រើក្នុងវិធីណាមួយដែលមានតែអ្នកប៉ុណ្ណោះដែលដឹង។

**ឧទាហរណ៍**

ប្រយោគ៖ My parents play cards twice a week.

ពាក្យសម្ងាត់មេ៖ mPpC#2aW

គេហទំព័រ៖ Gmail

ពាក្យសម្ងាត់ Gmail៖ mPpC#2aGmaWil

សហការផលិតដោយ

# ការស្វែងរកលើប្រព័ន្ធអ៊ិនធឺណិត

ដូចដែលបានដឹងហើយថា អ៊ិនធឺណិត គឺជាប្រព័ន្ធមួយដែលមនុស្សទូទាំងពិភពលោកកំពុងប្រើប្រាស់ជារៀងរាល់វិនាទី។ ដូចនេះនៅពេលអ្នកស្វែងរកព័ត៌មានលើប្រព័ន្ធអ៊ិនធឺណិត អ្នកត្រូវពិចារណា និងវិនិច្ឆ័យលើប្រភពរបស់ព័ត៌មានដែលទទួលឱ្យបានច្បាស់លាស់សិនមុននឹងឈានដល់ការសម្រេចចិត្តធ្វើអ្វីមួយ។ ខាងក្រោមនេះជាចំណុចសំខាន់ៗខ្លះដែលគួរដឹង និងរបៀបវាយតម្លៃលើគេហទំព័រ ដែល **'ត្រឹមត្រូវ'** មានន័យថាអ្នកគួរអនុវត្តតាម និង **'មិនត្រឹមត្រូវ'** មានន័យថាអ្នកមិនគួរអនុវត្តតាម។

| ត្រូវចងចាំ | ត្រឹមត្រូវ / មិនត្រឹមត្រូវ |
|---|---|
| ប្រសិនបើខ្ញុំអាចរកឃើញវានៅលើអ៊ិនធឺណិត វាច្បាស់ជាពិត។ | មិនត្រឹមត្រូវ |
| ខ្ញុំគួរពិនិត្យប្រភព និងអ្នកនិពន្ធគេហទំព័រជានិច្ច។ | ត្រឹមត្រូវ |
| មានអាសយដ្ឋានអ៊ីម៉ែលទំនាក់ទំនងនៅលើគេហទំព័រនោះ ដូច្នេះវាច្បាស់ជាគេហទំព័រដែលស្របច្បាប់។ | មិនត្រឹមត្រូវ |
| មាននិមិត្តសញ្ញារដ្ឋាភិបាលនៅផ្នែកខាងលើទំព័រ។ ខ្ញុំជឿជាក់លើគេហទំព័រនេះបាន។ | មិនត្រឹមត្រូវ |
| ខ្ញុំគួរតែធ្វើការប្រៀបធៀបព័ត៌មាន ដែលខ្ញុំបានរកឃើញនៅលើប្រព័ន្ធអ៊ិនធឺណិត ជាមួយប្រភពផ្សេងទៀត យ៉ាងហោចណាស់ពីរ។ | ត្រឹមត្រូវ |
| គេហទំព័រនោះមើលទៅហាក់ដូចជាផ្លូវការ។ ព័ត៌មានដែលមាននៅលើវាប្រាកដជាអាចជឿទុកចិត្តបាន។ | មិនត្រឹមត្រូវ |
| មានក្រាហ្វិក និងតារាងជាច្រើននៅលើគេហទំព័រ។ ព័ត៌មានទាំងនោះបញ្ជាក់ថាខ្ញុំអាចជឿទុកចិត្តបាន។ | មិនត្រឹមត្រូវ |

សហការផលិតដោយ

Smart

មូលនិធិ ស.ឥ. CBRD Fund

## តើអ្វីទៅដែលអាចធ្វើឱ្យគេហទំព័រមួយអាចជឿទុកចិត្តបាន?

អ្នកធ្វើការវាយតម្លៃបានតាមតារាងខាងក្រោម ប្រសិនបើចម្លើយ "ទេ" លើសពី៣០% គេហទំព័រនោះមិនអាចទុកចិត្តបាន១០០% នោះទេ។ អ្នកគួរពិចារណារកគេហទំព័រផ្សេង។

| ការវាយតម្លៃគេហទំព័រ | បាទ/ចាស | ទេ |
|---|---|---|
| **សមត្ថភាពរបស់អ្នកនិពន្ធ**<br>• តើវាមានភាពច្បាស់លាស់ថាអ្នកណាជាអ្នកសរសេរអត្ថបទនោះដែរទេ?<br>• តើអ្នកនិពន្ធជាអ្នកជំនាញលើប្រធានបទនោះដែរទេ? តើពួកគេមានកេរ្តិ៍ឈ្មោះល្អដែរទេ?<br>• តើអ្នកអាចបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មានទំនាក់ទំនងបានដែរទេ? | | |
| **ភាពត្រឹមត្រូវ**<br>• តើអ្នកគិតថាមាតិកានោះមានភាពត្រឹមត្រូវដែរទេ?<br>• តើមានកំហុសអក្ខរាវិរុទ្ធ ឬវេយ្យាករណ៍ដែរទេ?<br>• ប្រសិនបើមានរូបភាពនៅលើគេហទំព័រនោះ តើអ្នកគិតថាវាពិតដែរទេ? | | |
| **ភាពពេញលេញ**<br>• តើអ្នកគិតថាព័ត៌មាននោះមានភាពពេញលេញ និងមិនខ្វះចន្លោះដែរទេ?<br>• តើមានពាណិជ្ជកម្មនៅលើគេហទំព័រនោះដែរទេ? តើពួកវាពាក់ព័ន្ធនឹងអត្ថបទនោះដែរទេ? | | |
| **ការអាប់ដេត (ការធ្វើបច្ចុប្បន្នភាព)**<br>• តើអ្នកអាចមើលថាអត្ថបទនោះត្រូវបានបង្កើតឡើងនៅពេលណាទេ?<br>• តើអ្នកអាចមើលថាមាតិកានោះត្រូវបានអាប់ដេតនៅពេលណាទេ?<br>• តើមានតំណភ្ជាប់ (Link) ទាំងឡាយណាដែលមិនដំណើរការដែរទេ? | | |
| **ការគ្របដណ្តប់**<br>• តើប្រធានបទនោះត្រូវបានពន្យល់ជាលក្ខណៈស៊ីជម្រៅដែរទេ?<br>• តើអ្នកអាចរកឃើញព័ត៌មានដែលអ្នកកំពុងស្វែងរកបានទេ?<br>• តើតំណភ្ជាប់ទាំងនោះនាំអ្នកទៅកាន់ប្រភពព័ត៌មានល្អៗដែរទេ? | | |

សហការផលិតដោយ
មូលនិធិ ស.អ. CBRD Fund

# ការបោកប្រាស់លើប្រព័ន្ធអ៊ិនធឺណិត

មនុស្សរាប់លាននាក់កំពុងតែប្រើប្រាស់អ៊ិនធឺណិតជារៀងរាល់វិនាទី មានទាំងអ្នកដែលមានបំណងល្អ និងអ្នកដែលមានបំណងមិនល្អ។ ដូចនេះហើយ អ្នកប្រហែលក្លាយជាជនរងគ្រោះពីការបោកប្រាស់លើអ៊ិនធឺណិត ប្រសិនបើអ្នកមិនដឹងពីរបៀបក្នុងការការពារខ្លួននៅពេលដែលប្រើប្រាស់វា តែកុំបារម្ភព្រោះមានរបៀបសម្គាល់ការបោកប្រាស់លើអ៊ិនធឺណិតរបៀបជៀសវាង និងអ្វីដែលអ្នកគួរធ្វើនៅពេលដឹងថាអ្នកកំពុងត្រូវបានគេបោកប្រាស់៖

| របៀបសម្គាល់ការបោកប្រាស់លើអ៊ិនធឺណិត | |
|---|---|
| តើវាផ្ដល់ជូនអ្វីមួយឱ្យអ្នកដោយឥតគិតថ្លៃឬទេ? | ជាទូទៅការផ្ដល់ជូនដោយឥតគិតថ្លៃ ឬអ្វីដែលល្អស្ទើរមិនគួរឱ្យជឿ គឺជាការបោកប្រាស់ដើម្បីទទួលយកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។<br>ឧទាហរណ៍៖ 'ការធ្វើតេស្តអំពីចរិតលក្ខណៈ' គឺជាវិធីមួយនៃការប្រមូលទិន្នន័យអំពីអ្នក ដែលជាមធ្យោបាយងាយស្រួលក្នុងការទស្សន៍ទាយពីឈ្មោះអ្នកប្រើ និងពាក្យសម្ងាត់របស់អ្នក។ |
| តើអ្នកត្រូវបានស្នើឱ្យផ្ដល់ព័ត៌មានលម្អិតផ្ទាល់ខ្លួនឬ? | អាជីវកម្មដែលស្របច្បាប់ភាគច្រើននឹងមិនស្នើសុំព័ត៌មានផ្ទាល់ខ្លួននោះទេ (លេខគណនី, ពាក្យសម្ងាត់, លេខសម្ងាត់។ល។) តាមរយៈអ៊ីម៉ែល ឬសារតាមបណ្ដាញសង្គមនោះទេ។ |
| តើវាគឺជាសារតម្រូវឱ្យបញ្ជូនបន្តឬ? | សារតម្រូវឱ្យបញ្ជូនបន្តអាចធ្វើឱ្យអ្នកមានគ្រោះថ្នាក់។ កុំបញ្ជូនពួកវាបន្តទៅកាន់អ្នកដទៃ។ |

សហការផលិតដោយ

មូលនិធិ ស.ឥ.
CBRD Fund

| របៀបជៀសវាងពីការបោកប្រាស់លើអ៊ីនធឺណិត | |
|---|---|
| គិតមុនពេលចុច | កុំចុចលើតំណ ឬឯកសារភ្ជាប់ទាំងឡាយណានៅក្នុងអ៊ីម៉ែលដែលគួរឱ្យសង្ស័យ។ |
| ជៀសវាងការចុចលើគេហទំព័រដែលលោតឡើង (pop-up) | អ្នកទំនងជាមិនឈ្នះការប្រកួត ឬការបញ្ចុះតម្លៃណាមួយឡើយ។ ជាទូទៅសារទាំងនេះមានគោលបំណងប្រមូលព័ត៌មានរបស់អ្នក ឬចម្លងមេរោគទៅកុំព្យូទ័រអ្នក។ |
| កុំឆ្លើយតបនឹងអ៊ីម៉ែលដែលសួររកព័ត៌មានផ្ទាល់ខ្លួន | ធ្វើការស្រាវជ្រាវលើឈ្មោះក្រុមហ៊ុនលើអ៊ីនធឺណិត ឬសាកសួររកជំនួយពីបងប្អូន ឬអ្នកណាដែលអ្នកគិតថាពួកគាត់មានបទពិសោធខាងផ្នែកនោះ មុនពេលផ្តល់ព័ត៌មានផ្ទាល់ខ្លួនណាមួយ។ |
| អានបន្ថែមនូវព័ត៌មានលម្អិតដែលមាននៅលើអត្ថបទ | ទំព័រនោះអាចនឹងនិយាយថាអ្នកបានឈ្នះថេប្លេត (Tablet) មួយគ្រឿង ប៉ុន្តែប្រសិនបើអ្នកអានបន្ថែមនូវព័ត៌មានលម្អិតដែលមាននៅលើអត្ថបទ អ្នកនឹងឃើញថាអ្នកត្រូវបង់ប្រាក់ $២០០ ក្នុងមួយខែដើម្បីទទួលបានវា។ ដូច្នេះ គប្បីកុំតប ឬធ្វើការផ្ញើរសាច់ប្រាក់ទៅកាន់គេហទំព័រនោះ។ |

| អូ ទេ! ខ្ញុំគិតថាវាជាការបោកប្រាស់។ តើខ្ញុំត្រូវធ្វើដូចម្តេច? | |
|---|---|
| ប្រាប់បងប្អូន ឬអ្នកណាដែលអ្នកគិតថាពួកគាត់មានបទពិសោធខាងហ្នឹង និងអាចទុកចិត្តបាន | ប្រសិនបើអ្នកចាំកាន់តែយូរ អ្នកអាចនឹងជួបបញ្ហាកាន់តែធំ។ |
| ប្រសិនបើអ្នកមានការបារម្ភចំពោះគណនីធនាគារ ឬកាតឥណទានរបស់អ្នក | ទាក់ទងទៅធនាគារ ឬប្រតិបត្តិការកាតឥណទានរបស់អ្នកជាបន្ទាន់។ |
| ប្រសិនបើអ្នកទទួលបានសារបោកប្រាស់តាមរយៈអ៊ីម៉ែល ឬបណ្តាញសង្គមរបស់អ្នក | អ្នកអាចលុបវាចោល ឬរាយការណ៍វាទៅបណ្តាញសង្គមរបស់អ្នក ហើយបើនៅតែមានទៀត សូមរកជំនួយពីបងប្អូន ឬអ្នកណាដែលអ្នកទុកចិត្តបាន។ |

សហការផលិតដោយ

# ផ្នែកទី២

## ហ្គូហ្គល (Google)

---

ហ្គូហ្គល (Google) ជាក្រុមហ៊ុនបច្ចេកវិទ្យាចម្រុះរបស់
សហរដ្ឋអាមេរិក ដែលមានជំនាញលើផ្នែក
អ៊ិនធឺណិត និងផលិតផលផ្សេងទៀតដូចជា Google Play,
YouTube, Google Workspace, online advertising
technologies, cloud computing, software, និង
hardware។

បេសកកម្មរបស់ Google គឺរៀបចំព័ត៌មាន និងធ្វើឱ្យមានភាពទូលំទូលាយក្នុងការប្រើប្រាស់។ ដូច្នេះ អ្នកនឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ប្រសិនបើអ្នកប្រើប្រាស់បានត្រឹមត្រូវ។

ក្នុងសៀវភៅមួយនេះ អ្នកនឹងបានរៀនពីរបៀបក្នុងការប្រើប្រាស់ Google Workspace ដែលជាកម្មវិធីអាចឱ្យគ្រប់គ្នារួមទាំងសិស្សានុសិស្ស ភ្ជាប់ទំនាក់ទំនង សហការ ជាមួយមនុស្សជាច្រើន សម្រាប់ការប្រកបការងារ បំពេញកិច្ចការផ្ទះ (Homework) និងគ្រោងការងារផ្សេងៗទៀត។

**ដើម្បីចាប់ផ្តើម អ្នកត្រូវបង្កើត Google Account ជាមុនសិន។ ខាងក្រោមនេះជាជំហានលម្អិតដែលអ្នកអាចធ្វើតាមបាន។**

១




ចុចលើ Google App* និង វាយពាក្យ "Google Account" នៅលើ search bar

២




ចុចលើ "Create your Google account"

៣




ចុចលើ "សម្រាប់ខ្លួនខ្ញុំ"

៤




បំពេញព័ត៌មានដូចបង្ហាញខាងក្រោម

៥




បំពេញព័ត៌មានថ្ងៃខែឆ្នាំកំណើត

៦



ចុចលើ **"ខ្ញុំយល់ព្រម"**

៧




Account ត្រូវបានបង្កើត

សហការផលិតដោយ

# Google Workspace

**Google Workspace** ជួយសម្រួលដល់អ្នកប្រើប្រាស់ក្នុងការសិក្សារៀនសូត្រ គម្រោង ការងារជាក្រុម និងអាជីវកម្មប្រចាំថ្ងៃ។ **Google Workspace** ជួយធ្វើឱ្យផលិតភាពការងារ និង ការសហការរបស់សមាជិកក្រុម ដែលអនុញ្ញាតឱ្យពួកគេអាចធ្វើបច្ចុប្បន្នភាពការងាររបស់ពួកគេក្នុងក្រុម និងធ្វើទំនាក់ទំនងបានរហ័ស។

## ការបង្ហាញទូទៅរបស់ Google Workspace

- Google Drive: ប្រើដើម្បីរក្សាទុក ចែករំលែក និងសហការធ្វើការងារលើឯកសាររួម ពីទូរសព្ទ tablet, ឬកុំព្យូទ័រ។
- Google Docs: ប្រើដើម្បីបង្កើតឯកសារទូទៅ។
- Google Slides: ប្រើដើម្បីបង្កើតឯកសារសម្រាប់ធ្វើបទបង្ហាញ ។
- Google Sheets: ប្រើដើម្បីបង្កើតតារាង និងបញ្ជី។
- Google Meet: ប្រើដើម្បីវីដេអូ call ជាមួយលោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់ផ្សេងទៀត។




អំពី Google Workspace ជាភាសាខ្មែរ សូមចូលតាមតំណភ្ជាប់ (Link) នៅទំព័រឯកសារយោង។

### អ្វីជា Google Drive និងផលប្រយោជន៍របស់វា?

ជាមួយ Google Drive អ្នកអាចរក្សាទុក ចែករំលែក និងសហការធ្វើការងារលើឯកសាររួម ពីទូរសព្ទ tablet, ឬ កុំព្យូទ័រ។ បន្ថែមពីលើ web interface, Google Drive ផ្តល់ជូននូវ apps ជាមួយនឹង offline capabilities សម្រាប់ Windows និង macOS computers, Android, iOS smartphones និង tablets. សមត្ថភាពរក្សាទុកមានរហូតដល់ 15GB ដែលមិនទាមទារឱ្យបង់ប្រាក់។
អ្នកអាចរក្សាទុក ចែករំលែក និងចូលទៅកាន់ឯកសារបានគ្រប់ទីកន្លែង គ្រប់ពេលវេលា ដោយមិនមានការបារម្ភ។

## ការបង្ហាញទូទៅរបស់ Google Drive



# នៅក្នុង Google Drive

ដើម្បីរៀបចំឯកសាររបស់អ្នក អ្នកគួរតែបង្កើត folder ដែលមានឈ្មោះត្រឹមត្រូវ ដើម្បីរក្សាទុកនូវឯកសារដែលមានប្រភេទខុសគ្នា។ ឧទាហរណ៍ កេសរចង់រក្សាទុកនូវ ឯកសារ docx' files នៅក្នុង folder មួយ ដោយដាក់ឈ្មោះ “Kesor_Document។ អ្នកអាចប្រើប្រាស់ “_” ដើម្បីចែករវាងពាក្យនៅក្នុងឈ្មោះនោះ។ ខាងក្រោមនេះ អ្នកនឹងបានរៀនពីរបៀបក្នុងការបង្កើត folder រក្សាទុកឯកសារក្នុង Drive (In My Drive or Folder) និងចែករំលែកវាជាមួយអ្នកដទៃ។

## របៀបបង្កើត Folder




# រក្សាទុកឯកសារនៅក្នុង Drive





### វិធីសាស្ត្រទី ១

Upload ទៅកាន់ “ថាសរបស់ខ្ញុំ” (My Drive)

ចុចលើ“ថាសរបស់ខ្ញុំ”

ចុចលើ“ផ្ទុកឯកសារឡើង”

ចុចលើឯកសារដែលអ្នកចង់រក្សាទុកក្នុង My Drive

### វិធីសាស្ត្រទី ២

Upload ទៅកាន់ Folder “Kesor_Document”

ចុចលើ“Kesor_Document”

ចុចលើ“ផ្ទុកឯកសារឡើង”

ចុចលើឯកសារដែលអ្នកចង់រក្សាទុកក្នុង My Drive

នៅលើ Google Drive អ្នកអាចធ្វើការរក្សាទុកឯកសារលើប្រព័ន្ធអ៊ិនធឺណិត ហើយអ្នកអាចឱ្យអ្នកដទៃចូលទៅកាន់ឯកសារនោះតាមរយៈការ invite តាមអ៊ីម៉ែល ឬផ្ញើតំណភ្ជាប់នៃឯកសារនោះពី Google Drive ទៅកាន់ពួកគេ។ អ្នកនឹងបានរៀនពីវិធីសាស្ត្រនេះនៅផ្នែកបន្ទាប់ទៀត។

វាពិតជាមានសារៈសំខាន់ណាស់ដែលក្រុមការងារ ឬមិត្តរួមថ្នាក់របស់អ្នក អាចធ្វើការបាននៅលើឯកសារតែមួយ ដែលមានការអនុញ្ញាតពីម្ចាស់ឯកសារ ដូច្នេះអ្នកទាំងអស់គ្នាអាចធ្វើការបន្ថែម ឬកែសម្រួលលើឯកសារនោះក្នុងពេលជាមួយគ្នា។ ជាមួយនឹង Google Account អ្នកអាចចូលទៅកាន់ឯកសារបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលអ្នកត្រូវការ ដោយពុំចាំបាច់មានកុំព្យូទ័រផ្ទាល់ខ្លួនជាប់ជាមួយ។

# បង្កើតតំណភ្ជាប់ និងចែករំលែក ឯកសារ

## បង្កើតតំណភ្ជាប់ដើម្បីចែករំលែកជាមួយអ្នកដទៃ




### ត្រូវចងចាំ

មុនពេលចែករំលែក ឬយកតំណ ឱ្យនរណាម្នាក់ទៀត សូមពិនិត្យមើលទស្សនិកជនរបស់ឯកសារហ្នឹង។ នេះជាជម្រើសដែលមាន៖

ក. បើជ្រើសរើសយក “អ្នកមើល” មានន័យថាអ្នកដទៃបានត្រឹមមើលឯកសារតែប៉ុណ្ណោះ

ខបើជ្រើសរើសយក “អ្នកផ្តល់មតិ” មានន័យថាអ្នកដទៃបានមើលឯកសារ ហើយអាចបញ្ចេញមតិលើឯកសារបាន

គ. បើជ្រើសរើសយក “អ្នកកែ” មានន័យថាអ្នកដទៃបានមើលឯកសារ អាចបញ្ចេញមតិ ហើយកែលើឯកសារបាន

តោះចាប់ផ្តើមស្វែងយល់បន្ថែមពី Apps ចំនួន៣ទៀតរបស់ Google Workspace ដែលអាចជួយសម្រួលដល់ការធ្វើការ និង ក
សិក្សារបស់អ្នក។

## Google Docs

Google Docs អ្នកអាចបង្កើតឯកសារទូទៅ ផែនការបង្រៀន និងឯកសារប្រភេទផ្សេងៗទៀត។




## Google Slides

Google Slides អ្នកអាចបង្កើតជាឯកសារសម្រាប់ធ្វើបទបង្ហាញ កិច្ចការផ្ទះ (Homework) និងគម្រោងផ្សេងៗទៀត។




## Google Sheets

Google Sheets អ្នកអាចបង្កើតជាតារាង បញ្ជី និងការងារផ្សេងៗទៀតដែលទាក់ទងនឹងការទូទាត់។




សហការផលិតដោយ

# Google Meet

ការប្រជុំ ឬរៀនតាមវីដេអូត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ជាពិសេសក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ព្រោះវាបង្កលក្ខណៈងាយស្រួលយ៉ាងខ្លាំងសម្រាប់ការបង្រៀន និង  ការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស និងគ្រូបង្រៀន រួមទាំងការប្រជុំផ្សេងៗដោយពុំចាំបាច់មានការជួបផ្ទាល់។ មានកម្មវិធីជាច្រើនដូចជា Zoom, Microsoft Teams និង Google Meet ដែលអ្នកទាំងអស់គ្នាអាចប្រើបានសម្រាប់ការប្រជុំ ឬរៀនតាមវីដេអូ។ ខាងក្រោមនេះជាការ ណែនាំពីរបៀបប្រើប្រាស់ Google Meet ដែលជាកម្មវិធីមួយរបស់ Google Workspace។ តាមពិតទៅក៏មានលក្ខណៈស្រដៀងគ្នាដែរ មានន័យថា នៅពេលអ្នកទាំងអស់គ្នាចេះប្រើ Google Meet អ្នកក៏អាចយល់ដឹងពីរបៀបប្រើប្រាស់កម្មវិធីផ្សេងៗដែរ។

## របៀបប្រើប្រាស់ Google Meet

១ ចុចលើ Google App




២ ចុចលើ “ការប្រជុំថ្មី”

៣ ជ្រើសរើសជម្រើសដែលមាន









# អំឡុងពេលប្រជុំអ្នកអាច








១ បង្ហាញអេក្រង់ទាំងមូលរបស់អ្នក




អ្នកអាចឆ្លើយឆ្លងសារជាអក្សរនៅទីនេះបាន។ វាល្អសម្រាប់ការសួរសំណួរ ទម្លាក់តំណភ្ជាប់ ឬលេងហ្គេមផ្សេងៗ។

២ បង្ហាញអេក្រង់ណាដែលអ្នកជ្រើសរើស




៣ នេះជាជម្រើសល្អ បើអ្នកចង់បង្ហាញអេក្រង់ដែលកំពុងចាក់ជាសំឡេង ឬវីដេអូទៅការប្រជុំ។ អ្នកដែលនៅក្នុងការប្រជុំ អាចស្ដាប់លឺ និងមើលឃើញវីដេអូដែលអ្នកកំពុងចាក់។

សហការផលិតដោយ

មូលនិធិ ស.ស. CBRD Fund

# ផ្នែកទី៣
## ជំហានសម្រាប់ការបង្កើតទំព័រហ្វេសប៊ុក
## (Facebook Page)

---

ដូចដែលអ្នកបានដឹងហើយថា Facebook ជាបណ្ដាញទំនាក់ទំនងសង្គមមួយដែលពេញនិយមប្រើទូទាំងពិភពលោក។ គណនី Facebook ផ្ទាល់ខ្លួនមួយអាចអោយអ្នកបង្កើតមិត្តភក្តិ (Add Friend) បានត្រឹមតែប្រាំពាន់នាក់ប៉ុណ្ណោះ។ ដូចនេះ បើអ្នកចង់ធ្វើមាតិកា (អាចជាវីដេអូ ការសរសេរអត្ថបទ ឬរូបភាពផ្សេងៗដែលអាចមានអ្នកគាំទ្ររាប់រយហូតដល់ខ្ទង់លាន រយលាន ឬពាន់លាន អ្នកចាំបាច់ត្រូវបង្កើត Facebook Page មួយ។

## ខាងក្រោមនេះជារបៀបបង្កើតគណនី Facebook Page ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។

១







**ជំហានទី១** ចុចប៊ូតុង “Page” បន្ទាប់មក ចុចប៊ូតុង “Create” ។

២




**ជំហានទី២** ចុចប៊ូតុង "Get Started" រួចរើសប្រភេទ Page របស់អ្នក។




ជ្រើសរើស ឬបញ្ចូលពាក្យណាដែលពិពណ៌នា Page របស់អ្នក។

៣




**ជំហានទី៣** គ្រាន់តែដាក់ឈ្មោះ Page ជាការស្រេច។




ករណីវាមានអ្វីផ្សេងទៀតលោតចេញមក អ្នកទាំងអស់គ្នាគ្រាន់តែចុច “Skip” ជាការស្រេច ព្រោះព័ត៌មានទាំងនោះយើងអាចដូរពេលក្រោយបាននៅក្នុង Page របស់អ្នក។

៤




**ជំហានទី៤** គ្រាន់តែចុច Next ជាការស្រេចព្រោះព័ត៌មានទាំងនោះយើងអាចដូរពេលក្រោយបាននៅក្នុង Page។




ចុងក្រោយ ដាក់រូបភាពមួយឱ្យ Page របស់អ្នកដោយគ្រាន់តែចុចលើសញ្ញាបូក (+) នៅទីនេះ។

សហការផលិតដោយ

# ផ្នែកទី៤
## ការផលិតវីដេអូដោយប្រើប្រាស់ស្មាតហ្វូន (Smartphone)

---

វីដេអូជាមធ្យោបាយមួយដ៏ល្អក្នុងចំណោមមធ្យោបាយជាច្រើន ដែលត្រូវបានប្រើប្រាស់សម្រាប់ផ្សព្វផ្សាយ ផ្តល់ជាសារ ឬព័ត៌មានលើប្រធានបទណាមួយ ដោយសារវីដេអូមានរូបភាពចលនា ពណ៌ និងសំឡេង ដែលបញ្ជាក់ពីអារម្មណ៍ច្បាស់លាស់ និងអាចកំណត់រួចជាស្រេចថាអ្នកមើលជាអ្នកណា។ វីដេអូមានជាច្រើនប្រភេទ ប៉ុន្តែខាងក្រោមនេះយើងនឹងយកការធ្វើវីដេអូ Vox Pop មកចែករំលែកជាមួយអ្នកទាំងអស់គ្នា ព្រោះវាមានភាពងាយស្រួលក្នុងការចាប់ផ្តើមជាមួយ smartphone របស់អ្នក។

*សូមបញ្ជាក់ផងដែរថា មេរៀន និងខ្លឹមសារទាំងអស់នៃការផលិតវីដេអូដោយប្រើប្រាស់ smartphone ដែលមានខាងក្រោមនេះត្រូវបានដកស្រង់ចេញពីសៀវភៅ “វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះវីដេអូ” ដែលជាសៀវភៅផលិតឡើង ក្រោមជំនួយសប្បុរសរបស់ប្រជាពលរដ្ឋសហរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

# វីដេអូ Vox Pop

វីដេអូ Vox Pop ជាប្រភេទវីដេអូដែលអ្នកផលិតសួរមតិយោបល់ពីមនុស្សនៅតាមទីសាធារណៈពាក់ព័ន្ធនឹងប្រធានបទជាក់លាក់ណាមួយ។ វាជាប្រភេទវីដេអូដែលយើងប្រើសំណួរតែមួយ សួរទៅកាន់មនុស្សច្រើននាក់។

## តើវីដេអូ Vox Pop មួយដែលល្អគួរមានលក្ខណៈយ៉ាងណា?

- សួរមនុស្សផ្សេងៗគ្នាប្រើសំណួរតែមួយ តែត្រូវច្បាស់ថាពួកគេយល់សំណួរមុននឹងឆ្លើយ ដែលសំណួរនេះ ជាសំណួរខ្លី សាមញ្ញ និងងាយយល់
- សួរចំនួនស្មើគ្នារវាងមនុស្សប្រុស និងស្រី
- កុំសួរនៅតែមួយកន្លែង ដើម្បីបានទេសភាពផ្សេងៗគ្នា
- សួរមនុស្សគ្រប់ប្រភេទ ក្មេង ចាស់ ប្រុស ស្រី ឬ មនុស្សដែលមានអាជីពខុសៗគ្នា ដើម្បីទទួលបានចម្លើយ និងមតិខុសៗគ្នា ហើយទីកន្លែងផ្សេងៗគ្នា
- គួរព្យាយាមរកអ្នកដែលអាចឆ្លើយសំណួរដោយអារម្មណ៍ផ្សេងៗគ្នា ដូចជាខឹង សប្បាយ ឬទុក្ខព្រួយ។

**គួរចងចាំ៖** ចំណុចសំខាន់នៃការធ្វើវីដេអូ Vox Pop គឺជាការឆ្លុះបញ្ចាំងមតិផ្សេងៗគ្នារបស់មនុស្សផ្សេងៗគ្នាលើប្រធានបទតែមួយ។

| ឧទាហរណ៍៖ | |
|---|---|
| ឈ្មោះអ្នកផលិត | មករា |
| ទម្រង់វីដេអូ | Video Vox Pop |
| រយៈពេល | ២នាទី សម្រាប់ផ្សាយនៅលើ Facebook |
| ប្រធានបទ | ចរាចរណ៍ |
| គោលបំណង | បង្ហាញពីផលប៉ះពាល់នៃការស្ទះចរាចរណ៍ |
| អ្នកមើល | ប្រជាជនទូទៅ ជាពិសេសអ្នករស់នៅទីក្រុងភ្នំពេញ |
| សារ | រួមគ្នាគោរពច្បាប់ចរាចរណ៍ដើម្បីជៀសវាងការកកស្ទះចរាចរណ៍ |
| សង្ខេបអំពីវីដេអូ | វីដេអូនេះនិយាយអំពីផលប៉ះពាល់នៃការកកស្ទះចរាចរណ៍ និងលើកទឹកចិត្តឱ្យប្រជាជនទាំងអស់គោរពច្បាប់ចរាចរណ៍ដើម្បីជៀសវាងការកកស្ទះ។ |
| អ្នកដែលត្រូវបានសម្ភាសនៅទីតាំងថត | អ្នកលក់ដូរ សិស្ស អ្នកធ្វើដំណើរ អ្នករត់ម៉ូតូឌុប និងកង់បី<br>ផ្សារកាប់គោ សាលាបាក់ទូក តាមផ្លូវ២៧១ ជិតវត្តសន្សំកុសល |
| សំណួរ | សំណួរ Vox Pop: តើអ្នកយល់ថាការស្ទះចរាចរណ៍បណ្តាលមកពីមូលហេតុអ្វី? |
| B-Roll | សកម្មភាពអ្នកលក់ដូរតាមដងផ្លូវ, សិស្ស និងអ្នកធ្វើដំណើរតាមផ្លូវ អ្នករត់ម៉ូតូឌុប និងកង់បីចាំភ្ញៀវ, ផ្លូវដែលមានចរាចរណ៍កកស្ទះ |

សហការផលិតដោយ
មូលនិធិ ស.អ. CBRD Fund

# ការថត ប៊ីរ៉ូល B-Roll

B-Roll គឺជាវីដេអូបន្ថែម ដែលជួយបង្គ្រប់ន័យ ទៅលើវីដេអូ ចម្បងដែលជា A-Roll។ បើសិនជាបទសម្ភាសអ្នកជា A-Roll នោះអ្វីផ្សេងទៀតដែលដាក់បន្ថែមនៅក្នុងវីដេអូជា B-Roll ។

ដើម្បីធ្វើ B-Roll ឱ្យបានល្អ អ្នកគួរតែ៖

### ក. ធ្វើឱ្យមានភាពពាក់ព័ន្ធគ្នា

B-Roll គួរតែទាក់ទងទៅនឹងអ្វីដែលបានលើកឡើងក្នុងបទសម្ភាស។ បើរូបភាពមិនមានការទាក់ទងអត្ថន័យសម្ភាសន៍ នោះនាំឱ្យមានការរំខាន។

### ខ. រៀបចំទុកជាមុន ហើយអាចកែសម្រួលជាបន្តបន្ទាប់

- **B-Roll សម្រាប់ការនិទាន៖** យើងគួរតែគិតដល់ B-Roll ពេលយើងចាប់ផ្តើមធ្វើគម្រោងវីដេអូ ហើយកត់ត្រាទុកថាយើងត្រូវធ្វើ B-Roll អ្វីខ្លះ។ ថ្វីត្បិតតែការធ្វើ B-Roll អាចត្រូវត្រៀមទុក ជាមុន តែយើងក៏អាចកែសម្រួលជាបន្តបន្ទាប់ និងធ្វើ B-Roll បន្ថែមទៅតាមស្ថានភាពជាក់ស្តែងបានផងដែរ។
- **B-Roll សម្រាប់បទសម្ភាស៖** ពេលខ្លះយើងត្រូវធ្វើ B-Roll បន្ទាប់ពីយើងសម្ភាសហើយដោយយកទៅតាមអ្វីដែលបានលើកឡើងនៅក្នុងបទសម្ភាស។

### គ. ចលនាកាមេរ៉ា និងប្លង់ថត

អ្នកអាចថត B-Roll ដោយធ្វើឱ្យមានចលនាកាមេរ៉ា ឬប្លង់ផ្សេងៗគ្នា ដើម្បីជួយបញ្ជាក់ន័យក្នុងវីដេអូរបស់អ្នក។ អ្នកអាចថត B-Roll ដោយចាប់ផ្តើមពីប្លង់ទូលាយដោយទាញកាមេរ៉ាពីឆ្វេងទៅស្តាំ ឬពីលើចុះក្រោម និងថតការដើរចេញ ឬចូលក្លោងទ្វារ ដោយឱ្យអ្នកដែលយើងត្រូវសម្ភាសដើរឱ្យផុតពីប្លង់។

### ឃ. ព្យាយាមកាត់បន្ថយការរំខាន

យើងប្រើ B-Roll ដើម្បីជួយផ្តល់ព័ត៌មានបន្ថែម ដូចនេះបើ B-Roll នោះមិនសូវច្បាស់ គឺនាំឱ្យរំខានដល់វីដេអូរបស់អ្នក។ ដូចនេះគួរជ្រើសរើសរូបភាពណាដែលមិនមានភាពរំខាន។

### ង. ពេលវេលា

យើងអាចធ្វើប្លង់ B-Roll ពី២០ទៅ៣០វិនាទី តែវាក៏អាស្រ័យលើអ្នកដែលចង់បានផងដែរ។ បើរយៈពេលសរុបនៃបទសម្ភាសរបស់អ្នកគឺ ២នាទី អ្នកគួរធ្វើ B-Roll ៨ទៅ១០ប្លង់។

*អ្នកទាំងអស់គ្នាអាចរកមើលខ្លឹមសារទាំងស្រុងរបស់សៀវភៅ **"វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះវីដេអូ"** តាមតំណភ្ជាប់ (Link) នៅទំព័រឯកសារយោង និងធនធានផ្សេងៗបាន

# ការថតវីដេអូ និងការកាត់វីដេអូ

Video Sequence គឺជាការរៀបបញ្ចូលវីដេអូប្លង់ផ្សេងៗគ្នាអំពីអ្វីមួយដើម្បីឱ្យចេញជាសាច់រឿងមួយ។ ដូចនេះហើយ យើងត្រូវថតប្លង់ផ្សេងៗគ្នា មុំផ្សេងគ្នា ទីកន្លែងផ្សេងគ្នា រយៈចម្ងាយខុសគ្នា ។ល។ គ្រប់អ្វីទាំងអស់ដែលអ្នកចង់ថត ឬត្រូវថត ត្រូវចាំថាអ្នកគួរថតយ៉ាងហោចណាស់៤ ប្លង់ដូចជា Long shot, Medium shot និង Close up shot ចំនួនពីរផ្សេងគ្នា។ ជាទូទៅអ្នកមិនគួរណាប្រើប្លង់ Long shot ពីរជាប់គ្នានោះទេ។

## ក. ប្លង់ថត



**Rule of Thirds** គឺជាការថតដោយដាក់ចំណុចសំខាន់នៅចំណុចមួយភាគ៣នៃប្លង់ ដែលអាចនៅបញ្ឈរ ឬផ្ដេក។



**Lead Room** គឺជាការថតដោយទុកឱ្យមានចំណុចទូលាយក្នុងប្លង់ទៅតាមភ្នែករបស់មនុស្សដែលនៅក្នុងប្លង់ ឬទៅតាមទិសដៅកម្មវត្ថុដែលកំពុងមានចលនា។



**Extreme Close Up Shot** គឺជាការថតប្លង់ចង្អៀតដោយផ្ដោតទៅលើចំណុចតូចៗ ដើម្បីបង្ហាញអំពីភាពលម្អិត ឬអារម្មណ៍ជាក់លាក់ណាមួយ។



**Close Up Shot** ជាការថតត្រឹមក្បាលពេញមួយប្លង់តែម្ដង។



**Medium Close Up Shot** គឺជាការថតពាក់កណ្ដាលខ្លួនចាប់ពីក្បាលដល់ស្មា។



**Medium Shot** ជាការថតត្រឹមក្បាលចុះដល់ចង្កេះ។



**Long Shot** ជាការថតទូលាយឃើញពីក្បាលដល់ចុងជើង។





**Over the Shoulder Shot** គឺជាការថតពេលមនុស្សពីរនាក់សន្ទនាគ្នា ដោយថតពីស្មាមនុស្សម្នាក់ទៅមុខមនុស្សម្នាក់ទៀត។

សហការផលិតដោយ

## ខ. ចលនាកាមេរ៉ា







**Pan** ជាការថតយកប្លង់ដោយទាញកាមេរ៉ាពីឆ្វេងទៅស្តាំឬពីស្តាំទៅឆ្វេង។

**Tilt** ជាការថតយកប្លង់ដោយទាញកាមេរ៉ាពីលើចុះក្រោម ឬពីក្រោមឡើងទៅលើ។

# សេចក្តីណែនាំកម្មវិធីកាត់វីដេអូក្នុងទូរសព្ទដៃ

កម្មវិធីកាត់តវីដេអូតាមទូរសព្ទមានច្រើនប្រភេទ ដែលអាចផ្តល់នូវមុខងារផ្សេងៗគ្នាក្នុងការកាត់តវីដេអូ។ នៅក្នុងសៀវភៅមេរៀននេះ យើងនឹងលើកយកកម្មវិធីកាត់តវីដេអូចំនួនពីរយកមកបង្ហាញ។

*សម្រាប់ការណែនាំលម្អិត សូមអានសៀវភៅ **“វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះវីដេអូ”** ទំព័រ១៥ ដល់ ២៥ ដែលអាចរកបានតាមតំណភ្ជាប់ (Link) នៅទំព័រ ឯកសារយោង និងធនធានផ្សេងៗ។

| App | iMovie or Movie Maker (Android) | iMovie (iOS) |
|---|---|---|
| Function | √ | √ |
| A-Roll | √ | √ |
| B-Roll | √ | √ |
| Sound | √ | x |
| Watermark | √ | √ |
| Text | √ | x |
| Pro Version | x | x |
| Limited Duration | Android 4.1 or later | IOS 9.3 or later |
| Capacity Required | | |

# ឯកសារយោង និងធនធានផ្សេងៗ

- សៀវភៅ “កម្មវិធីសិក្សាអំពីភាពជាពលរដ្ឋឌីជីថល” ចូលតាមតំណភ្ជាប់ (Link)៖ bit.ly/Digital_Literacy_kh
- អំពី Google Workspace ជាភាសាខ្មែរ ចូលតាមតំណភ្ជាប់ (Link) ៖ bit.ly/GoogleWorkspace_kh
- សៀវភៅ “វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះវីដេអូ” ចូលតាមតំណភ្ជាប់ (Link)៖ bit.ly/VDOTraining
- វីដេអូទីមួយ ពន្យល់ពីការកាត់តវីដេអូតាមកម្មវីធីទូរសព្ទ៖ bit.ly/VDO_Editing1_kh
- វីដេអូទីពីរ ពន្យល់ពីការកាត់តវីដេអូតាមកម្មវីធីទូរសព្ទ៖ bit.ly/VDO_Editing2_kh
- វីដេអូទីបី ពន្យល់ពីការកាត់តវីដេអូតាមកម្មវីធីទូរសព្ទ៖ bit.ly/VDO_Editing3_kh
- វីដេអូពន្យល់ពីសុវត្ថិភាព ហ្វេសប៊ុក (Facebook Safety) ភាសាខ្មែរភាគ១៖ bit.ly/Facebook1_kh
- វីដេអូពន្យល់ពីសុវត្ថិភាព ហ្វេសប៊ុក (Facebook Safety) ភាសាខ្មែរភាគ២៖ bit.ly/Facebook2_kh
- វីដេអូពន្យល់ពីសុវត្ថិភាព ហ្វេសប៊ុក (Facebook Safety) ភាសាខ្មែរភាគ៣៖ bit.ly/Facebook3_kh
- វីដេអូពន្យល់ពីសុវត្ថិភាព ហ្វេសប៊ុក (Facebook Safety) ភាសាខ្មែរភាគ៤៖ bit.ly/Facebook4_kh
- វីដេអូពន្យល់ពីសុវត្ថិភាព ហ្វេសប៊ុក (Facebook Safety) ភាសាខ្មែរភាគ៥៖ bit.ly/Facebook5_kh
- ទាញយកសៀវភៅ “ការពង្រឹងជំនាញឌីជីថលដល់សហគ្រិនធនតូច និងមធ្យមនៅកម្ពុជា អំពីការគ្រប់គ្រងហ្វេសប៊ុក” តាមតំណនេះ(Link)៖ bit.ly/FacebookPage_Manual

Google, Google Drive, Google Docs, Google Slides, Google Sheets, and Google Meet are trademarks of Google LLC, and this book is not endorsed by or affiliated with Google in any way.

Facebook, YouTube, Wikipedia, Open Development Cambodia, and TikTok are trademarks of their respective brands, and this book is not endorsed by or affiliated with them in any way.

សហការផលិតដោយ



## ប្រាប់បានទេថាអ្នកនឹងធ្វើអ្វីខ្លះ ដើម្បីរក្សាសុវត្ថិភាពរបស់ខ្លួនអ្នកផ្ទាល់ ក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត?

## ហើយអ្នកនឹងបង្កើតទម្លាប់អ្វីខ្លះ ដើម្បីរក្សាសុវត្ថិភាពរបស់ខ្លួនអ្នកផ្ទាល់ ក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត?



សហការផលិតដោយ

# កំណត់ត្រាផ្ទាល់ខ្លួនពីការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត



សហការផលិតដោយ

សូមស្កេន QR code ទៅកាន់ហ្វេសប៊ុក Smart for Cambodia
រួចចុច Follow ដើម្បីទទួលបានព័ត៌មានបន្ថែមពីកម្មវិធីផ្សេងៗទៀត




សៀវភៅណែនាំអំពីអក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថលនេះត្រូវ
បានផលិតឡើងមិនសម្រាប់ការរកប្រាក់ចំណូល ប៉ុន្តែជាការគាំទ្រ
ទៅលើកម្មវិធីអក្ខរកម្មឌីជីថល និងភាពជាពលរដ្ឋឌីជីថលរបស់
ក្រុមហ៊ុន Smart Axiata Co., Ltd.។

សហការផលិតដោយ

Smart

មូលនិធិ ស.អ.
CBRD Fund